

Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 3.12 រឿងរ៉ាវរបស់នាងរស់

មានស្ត្រីម្នាក់ឈ្មោះណាអូមី។ នាង និងប្ដី ព្រមទាំងកូនប្រុសពីរនាក់បានសម្រេចចិត្តផ្លាស់ទីលំនៅពីកន្លែងដែលពួកគេរស់នៅក្នុងភូមិបេថ្លេហិមទៅស្រុកមួយទៀតហៅថាម៉ូអាប់។ នៅម៉ូអាប់ កូនប្រុសទាំងពីររបស់គេ បានរកឃើញក្មេងស្រីដែលពួកគេ ចង់រៀបការ។ កូនប្រុសម្នាក់បានរៀបការជាមួយក្មេងស្រីម្នាក់ឈ្មោះអ័រប៉ា។ កូនប្រុសមួយទៀតរៀបការជាមួយក្មេងស្រីម្នាក់ឈ្មោះរស់។

ប្ដីរបស់នាងណាអូមីបានស្លាប់មុនពេលកូនប្រុសរបស់ពួកគេរៀបការ ប៉ុន្តែនាងសប្បាយចិត្តដែលនៅតែមានកូនប្រុស និងប្រពន្ធរបស់ពួកគេដើម្បីបន្តពូជពីនាង។ ដប់ឆ្នាំក្រោយមក កូនប្រុសទាំងពីររបស់នាងបានស្លាប់។ បន្ទាប់មកណាអូមីមានទុក្ខព្រួយណាស់។ នាងចង់ត្រឡប់ទៅភូមិបេថ្លេហិមវិញ។ នាងបានប្រាប់ប្រពន្ធកូនប្រុសរបស់នាងទាំងពីរ ឱ្យត្រឡប់ទៅគ្រួសារពួកគេវិញ។ ប៉ុន្តែនាងរស់ចង់នៅជាមួយណាអូមី។ នាងរស់ប្រាប់ណាអូមីថា‶ ខ្ញុំនឹងទៅកន្លែងណាដែលអ្នកម្ដាយទៅ។ ខ្ញុំនឹងរស់នៅកន្លែងណាដែលអ្នកម្ដាយរស់នៅ។ ព្រះរបស់អ្នកម្ដាយនឹងក្លាយជាព្រះរបស់ខ្ញុំ ហើយខ្ញុំនឹងស្លាប់នៅកន្លែងណាដែលអ្នកម្ដាយស្លាប់″។ ដូច្នេះណាអូមី និងនាងរស់បានត្រឡប់ទៅបេថ្លេហិមជាមួយគ្នាវិញ។

នៅបេថ្លេហិម គឺវាដល់ពេលប្រមូលផលស្រូវឱកហើយ។ ដូចតទ្បូវដែរ អង្ករគឺជាអាហារចម្បងរបស់ពួកគេ។ ច្បាប់សាសន៍យូដាបាននិយាយថា កសិករមិនអាចច្រូតកាត់លើដីស្រែរបស់ខ្លួនបានទេ ដូច្នេះប្រជាជនក្រីក្រអាចមកទទួលយកបាន និងមានអាហារបរិភោគ។ ដូចគ្នានេះផងដែរ ប្រសិនបើដើមស្រូវត្រូវបានទម្លាក់នៅលើដី ក៏ត្រូវទុកវាសម្រាប់អ្នកក្រីក្រដែរ។ តាមវិធីនេះ ប្រជាជនក្រីក្រអាចរស់នៅបាន។ ណាអូមីមានសាច់ញាតិម្នាក់ឈ្មោះ បូអូសដែលមានដីស្រែធំ។ នាងបានប្រាប់នាងរស់ឲ្យទៅស្រែរបស់បូអូស ហើយប្រមូលស្រូវដែលជ្រុះចោលដើម្បីយកមកធ្វើជាអាហារបរិភោគ។

នាងរស់បានទៅចំការរបស់លោកបូអូស ហើយចាប់ផ្ដើមប្រមូលស្រូវ។ បូអូសចូលចិត្តនាងរស់ណាស់ ហើយចង់ការពារនាង។ គាត់ចង់ឲ្យនាងបានគួស្រូវល្អៗ ដែលនៅសល់ពីចំរូតរបស់កម្មករគាត់។ គាត់ដឹងថានាងបានត្រឡប់មកពីភូមិបេថ្លេហិមវិញដើម្បីនៅជាមួយណាអូមី ជាជាងស្នាក់នៅជាមួយម៉ូអាប់ជាមួយគ្រួសារនាងផ្ទាល់។គាត់មានប្រសាសន៍ទៅនាងថា៖«ព្រះអម្ចាស់ជាព្រះនៃជនជាតិអ៊ីស្រាអែលនឹងប្រទានរង្វាន់ឱ្យអ្នក»។ ណាអូមីសប្បាយណាស់ ដែលនាងរស់បានជួបបូអូសហើយបានទទួលស្រូវពីចម្ការរបស់គាត់។ ណាអូមីគិតថា ប្រហែលជានាងរស់ និងបូអូសគួរតែរៀបការជាមួយគ្នា។

លោកបូអូសបានគិតថា គាត់ចង់រៀបការជាមួយនាងរស់ ប៉ុន្តែមានទំនៀមទម្លាប់ជនជាតិយូដា ដែលនិយាយថា សាច់ញាតិដែលជិតស្និទ្ធបំផុត ទើបមានជម្រើសមុនគេ ដើម្បីរៀបការជាមួយនាងរស់ ប្រសិនបើគេចង់។ បន្ទាប់មកលោកបូអូសបានសួរទៅសាច់ញាតិជិតស្និទ្ធថា តើគាត់ចង់រៀបការជាមួយនាងទេ? បុរសនោះបានប្រាប់បូអូសថា គាត់មានប្រពន្ធរួចហើយ! បូអូសសប្បាយចិត្តណាស់ ។ ដូច្នេះ គាត់មានសេរីភាពរៀបការជាមួយនាងរស់បានហើយ ។ លោកបូអូស និងនាងរស់ក៏បានរៀបការជាមួយនឹងគ្នាទៅ ។ មនុស្សគ្រប់គ្នាសប្បាយរីករាយណាស់ រួមទាំងណាអូមីផងដែរ ។ មួយរយៈក្រោយមក នាងរស់ក៏មានកូនមួយ ។ នាងដាក់ឈ្មោះ ថា អូបិឌ ។ ច្រើនឆ្នាំបានកន្លងផុតទៅ អូបិឌបានក្លាយជាឪពុករបស់អ៊ីសាយ ។ ច្រើនឆ្នាំក្រោយមក អ៊ីសាយបានក្លាយជាឪពុករបស់ដាវីឌ ហើយដាវីឌបានក្លាយជាបុរសម្នាក់ ដែលស្រឡាញ់ព្រះយ៉ាងខ្លាំង ។ យើងនឹងរៀនបន្ថែមទៀតអំពីលោកដាវីឌនៅពេលក្រោយ!

**(នាងរស់ ជំពូក ១ - ៤)**

3.12 **រឿងរ៉ាវរបស់នាងរស់ - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន**

**កំណត់សម្គាល់**

1) ណាអូមី និងប្តីរបស់នាងបានផ្លាស់ពីបេថ្លេហិមទៅស្រុកម៉ូអាប់ជាមួយកូនប្រុសរបស់ពួកគេ។ កូនប្រុសរបស់ពួកគេបានជួបនិងរៀបការជាមួយក្មេងស្រីមកពីស្រុកម៉ូអាប់។
2) ប្តីរបស់ណាអូមីបានស្លាប់។ បន្ទាប់ពីដប់ឆ្នាំក្រោយមក កូនប្រុសរបស់គាត់ទាំងពីរក៏បានស្លាប់ទៀត។ នាងពិបាកចិត្តណាស់។ នាងនៅសល់តែប្រពន្ធកូនប្រុសរបស់នាងប៉ុណ្ណោះ។ នាងបានប្រាប់ពួកគេថា នាងត្រូវត្រឡប់ទៅភូមិបេថ្លេហិមវិញ នាងចង់ឱ្យពួកគេត្រឡប់ទៅជុំគ្រួសារគេវិញ។
3) នាងរស់ចង់នៅជាមួយណាអូមី។ នាងបានប្រាប់ន៉ាអូមីថា នាងចង់នៅជាមួយគាត់ ហើយរស់នៅកន្លែងណាដែលគាត់រស់នៅ និងស្លាប់នៅទីណាដែលនាងស្លាប់។ នាងរស់បាននិយាយថា "ព្រះរបស់អ្នកម្តាយនឹងធ្វើជាព្រះរបស់ខ្ញុំ"
4) នាងរស់ និងណាអូមីបានត្រឡប់ទៅភូមិបេថ្លេហិមវិញ។ នាងរស់បានរើសស្រូវដែលនៅសល់ពីចំការដែលជាកម្មសិទ្ធិរបស់សាច់ញាតិរបស់ណាអូមីឈ្មោះ បូអូស។
5) បូអូសចូលចិត្តនាងរស់ ហើយសម្រេចចិត្តរៀបការជាមួយនាង។ មនុស្សគ្រប់គ្នាសប្បាយរីករាយជាខ្លាំង។ នាងរស់ និងបូអូសបានមានកូនមួយជាមួយគ្នា ហើយដាក់ឈ្មោះថា អូបិឌ។ ក្រោយមកអូបិឌ មានកូនប្រុសមួយ ហើយដាក់ឈ្មោះគាត់ថា អ៊ីសាយ។ ក្រោយមកអ៊ីសាយមានកូនប្រុសមួយ ហើយដាក់ឈ្មោះថាដាវីឌ។ ដាវីឌបានក្លាយជាបុរសម្នាក់ដែលស្រឡាញ់ព្រះយ៉ាងខ្លាំង។

**សំណួរ**

1) តើនាងណាអូមីមកពីណា?
2) តើកូនប្រុសរបស់ន៉ាអូមីជួបប្រពន្ធនៅឯណា?
3) នៅពេលដែលកូនប្រុសរបស់ន៉ាអូមីទាំងពីរនាក់បានស្លាប់ តើនាងបានប្រាប់ប្រពន្ធកូនប្រុសរបស់នាងឱ្យធ្វើអ្វី?
4) តើនាងរស់បានសម្រេចចិត្តធ្វើអ្វី?
5) តើនាងរស់បានជួបប្តីរបស់នាងឈ្មោះបូអូសយ៉ាងដូចម្តេច?
6) តើដាវីឌមានទំនាក់ទំនងអ្វីនឹងនាងរស់ ជាមួយបូអូស?

**ចម្លើយ**

1) នាងណាអូមីមកពីភូមិបេថ្លេហិម។
2) កូនប្រុសរបស់ណាអូមីបានជួបប្រពន្ធរបស់ពួកគេនៅម៉ូអាប់។
3) បន្ទាប់ពីកូនប្រុសរបស់នាងបានស្លាប់ទៅ ណាអូមីបានប្រាប់ប្រពន្ធរបស់ពួកគេឱ្យត្រឡប់ទៅគ្រួសាររបស់ពួកគេវិញ។
4) នាងរស់បានសំរេចចិត្តស្នាក់នៅជាមួយន៉ាអូមី ។ ពួកគេបានត្រឡប់ទៅបេថ្លេហិមជាមួយគ្នា ។
5) នាងរស់បានជួបលោកបូអូសពេលនាងចាប់ផ្តើមរើសគួស្រូវដែលនៅសល់នៅក្នុងចម្ការរបស់គាត់ ។
6) នាងរស់ និងបូអូសគឺជាឪពុកម្តាយរបស់អូបិឌ ។ អូបិឌជាឪពុករបស់អ៊ីសាយ ។ អ៊ីសាយជាឪពុករបស់ដាវីឌ ។


Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org